## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៤ ខែ មិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ២៦៤,៥០២ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធធារាសាស្ត្រ និងកែលម្អបរិក្ខារអនាម័យក្នុងខេត្តសៀមរាប ខេត្តបាត់ដំបង និង ខេត្តកំពង់ចាម

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន (ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយ តូច សន្តិសុខ មនុស្សជាតិ ជំនួយ គូសាណូណិ) រដ្ឋាភិបាល ជប៉ុន បានផ្តល់ទឹកប្រាក់ សរុប ចំនួន២៦៤,៥០២ដុល្លាអាមេរិកដល់មន្ទីរធនធានទឹកនិងឧតុនិយមចំនួន២និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក១។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយទាំង៣សម្រាប់គម្រោងដូចតទៅ៖

<u>១. គម្រោងស្តារប្រទ្បាយមុខបួនក្នុងខេត្តបាត់ដំបង (១១៤,២៦៨ដុល្លាអាមេរិក)</u>
<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង</u>



គម្រោងនេះគឺដើម្បីស្តារប្រទ្បាយរងប្រវែង៨៥០ម៉ែត្រ សាងសង់ប្រទ្បាយទីបីប្រវែង១,០៥០ម៉ែត្រ និងសំណង់បញ្ចូលទឹកបីកន្លែង។ យើងសង្ឃឹមថាគម្រោងនេះនឹងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ប្រចាំឆ្នាំ ព្រមទាំងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាជនប្រមាណ៨០គ្រួសារក្នុងតំបន់។

<u>២. គម្រោងស្តារប្រទ្បាយលេខ៧ (SC7) ខេត្តសៀមរាប (១២១,៥៧៨ដុល្លាអាមេរិក)</u>
<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប</u>

គម្រោងនេះគឺដើម្បីស្តារប្រទ្បាយរងប្រវែង៣,៧០០ម៉ែត្រ និងសាងសង់ជញ្ជាំងការពារ ស្ពានបេតុង និងលូចំនួន១០កន្លែង។ យើងសង្ឃឹមថាគម្រោងនេះនឹងជួយកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ប្រចាំឆ្នាំ ព្រមទាំងសម្រួលដល់ការទទួលបានទឹកស្រោចស្រពដីស្រែសម្រាប់ប្រជាជនប្រមាណ១,៦០០គ្រួសារក្នុងតំបន់។



ជាមួយនឹងជំនួយបច្ចេកទេសពីមន្ទីរនិមួយៗ ប្រជាសហគមន៍ក្នុងតំបន់គោលដៅនឹងថែទាំប្រព័ន្ធធារាសាស្ត្រទាំងពីរនេះឲ្យបានល្អប្រសើរ។

__៣. គម្រោងកែលម្អបរិក្ខារអនាម័យក្នុងសាលាបឋមសិក្សា៦នៃស្រុកកងមាស និងស្រុកបាធាយ ខេត្ត កំពង់ចាម (២៨,៦៥៦ដុល្លាអាមេរិក)__
__ស្ថាប័នទទួលជំនួយ៖ អង្គការទឹកភ្លៀងកម្ពុជា__



គម្រោងនេះគឺដើម្បីសាងសង់អាងស្តុកទឹកភ្លៀងចំនួន៦ កន្លែង លាងដៃចំនួន៥ កន្លែងផឹកទឹកចំនួន៦និងបន្ទប់ទឹក១០ និងរុះរើបន្ទប់ទឹក៤ ព្រមទាំងជួសជុលបន្ទប់ទឹក១១ផ្សេងទៀត។ យើងសង្ឃឹមថាគម្រោងនេះនឹងជួយកែលម្អស្ថានភាពអនាម័យសម្រាប់ សិស្សានុសិស្សនិងលោកគ្រូ-អ្នកគ្រូប្រមាណ២,៤០០ក្នុងសាលាបឋមសិក្សាទាំង៦។

ជំនួយ *គូសាណូណេ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥០.៩លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥០៩ គម្រោងនៅទូទាំងប្រទេស។

